# សុន្ទរកថាបើក
# ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
# ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣
# និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២៤
# របស់ក្រសួងមុខងារសាធារណៈ

- ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ
- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា តំណាងក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សមាជិក សមាជិកានៃអង្គសន្និបាតទាំងមូល ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សក្រៃលែង ដោយបានចូលរួមជាអធិបតីក្នុងពិធីបើក**សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២៤** របស់ក្រសួងមុខងារសាធារណៈ ដ៏មានសារសំខាន់នាពេលនេះ។

ក្នុងនាមក្រសួងមុខងារសាធារណៈនិងរូបខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវអំណរគុណចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ដែលបានចូលរួមក្នុងអង្គសន្និបាតនាថ្ងៃនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណនិង

កោតសរសើរដល់ថ្នាក់ដឹកនាំ និងសមាជិកក្រុមការងារទាំងអស់របស់ក្រសួងមុខងារសាធារណៈ ដែលបានខិតខំរៀបចំអង្គសន្និបាតនេះឡើង ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់និងបរិយាកាសរីករាយ។

ក្នុងឱកាសនេះ ខ្ញុំសូមរំលឹកឡើងវិញជូនដល់អង្គពិធីឱ្យបានជ្រាបថា ចាប់តាំងពីត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៣ ដោយការរួមបញ្ចូលគ្នានូវស្ថាប័នចំនួន៣ គឺ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងសាលាភូមិន្ទរដ្ឋបាល ក្រសួងមុខងារសាធារណៈមានបេសកកម្មនិងភារកិច្ចដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈ និងការកែទម្រង់រដ្ឋបាលសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមលើនេះ នៅក្នុងនីតិកាលទី៧នៃរដ្ឋសភា ក្រសួងមុខងារសាធារណៈ ទទួលបាននូវភារកិច្ចថ្មីមួយបន្ថែមទៀត គឺជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា (ហៅកាត់ថា **គ.វ.រ.**) ដែលគណៈកម្មាធិការជាតិនេះ ដឹកនាំផ្ទាល់ដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងមានសមាសភាពជារដ្ឋមន្ត្រីពីគ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំង២៥។ ក្នុងនាមជាលេខាធិការដ្ឋាននៃគ.វ.រ. ក្រសួងមុខងារសាធារណៈ មានភារកិច្ច ដឹកនាំ សម្របសម្រួល ជំរុញ និងតាមដានការអនុវត្តវិធានការគន្លឹះចំនួនបី ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈគឺ **ទី១** ការកែលម្អប្រព័ន្ធជ្រើសរើស **ទី២** ការលើកកម្ពស់ប្រសិទ្ធភាពការងារ និង**ទី៣** ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម។

ផ្តើមចេញពីបេសកកម្មនិងភារកិច្ច ព្រមទាំងមានការគាំទ្រពីរាជរដ្ឋាភិបាល នីតិកាលកន្លងមក និងជាពិសេសរាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយនិងភាពស្វាហាប់របស់ **សម្តេចមហាបវរធិបតី** នៅក្នុងឆ្នាំ២០២៣និងដើមឆ្នាំ២០២៤កន្លងទៅនេះ ក្រសួងមុខងារសាធារណៈបានសម្រេចនូវសមិទ្ធផលសំខាន់ៗជាច្រើនគួរជាទីមោទនៈ។ នៅក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមគូសរំលេចនូវសមិទ្ធផលសំខាន់ៗមួយចំនួនជូនអង្គសន្និបាត ដូចខាងក្រោម៖

១. ក្រសួងបានធ្វើការពិនិត្យនិងវាយតម្លៃឡើងវិញរចនាសម្ព័ន្ធអង្គភាព និង មុខងាររបស់ខ្លួន ហើយបានធ្វើការកែទម្រង់ក្រសួង ដោយបានរៀបចំរចនាសម្ព័ន្ធក្រសួងឡើងវិញ ដើម្បីឱ្យសមស្របទៅនឹងអាទិភាពការងារគោលនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ដោយអង្គភាពខ្លះត្រូវបានច្របាច់បញ្ចូលគ្នា ដូចជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនិងអគ្គនាយកដ្ឋានកិច្ចការទូទៅ ត្រូវបានបញ្ចូលគ្នាទៅជាអគ្គលេខាធិការដ្ឋានរបស់ក្រសួង អង្គភាពខ្លះត្រូវបានលុបចេញនិងខ្លះទៀតត្រូវបានកែប្រែដោយផ្នែក ឬទាំងស្រុង។ ការកែសម្រួលនេះ ត្រូវបានអនុវត្តឈរលើមូលដ្ឋាននៃការវិភាគមុខងាររបស់ក្រសួងក៏ដូចជាការពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធអង្គភាព មុខងារ និង វិហ្សការងាររបស់គ្រប់អង្គភាពចំណុះ គួបផ្សំនឹងបទពិសោធនៃការអនុវត្តការងារកន្លងមកដោយផ្អែកលើរចនាសម្ព័ន្ធពីមុន បញ្ហាប្រឈម និង ការលំបាកនានាដែលមន្ត្រីនិងអង្គភាពជួបប្រទះ និងក្នុងគោលបំណងបង្កើនប្រសិទ្ធភាពការងារ កាត់បន្ថយនីតិវិធី និងការសម្របសម្រួលមិនចាំបាច់ផ្សេងៗ និងបង្កើនការទទួលខុសត្រូវរបស់អង្គភាពនីមួយៗ។ ជាលទ្ធផលនៃការកែសម្រួលរចនាសម្ព័ន្ធនេះ ការបំពេញការងាររបស់មន្ត្រីតាមអង្គភាពមានភាពរលូន និងកាន់តែមានប្រសិទ្ធភាព។ លើសពីនេះ ក្រសួងក៏បានធ្វើការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំ និងមន្ត្រីទាំងកម្រិតនយោបាយនិងបច្ចេកទេសឱ្យស្របនឹងការកែសម្រួលរចនាសម្ព័ន្ធក្រសួង ក៏ដូចជាតួនាទីភារកិច្ច និងបេសកកម្មរបស់ខ្លួន ជាពិសេសបេសកកម្មក្នុងការអនុវត្តវិធានការគន្លឹះទាំងបី ព្រមទាំងមានរបបប្រជុំត្រួតពិនិត្យនិងរាយការណ៍ជាទៀងទាត់ដើម្បីពិភាក្សាដោះស្រាយបានទាន់ពេលវេលានូវបញ្ហាប្រឈមនានា និង ធានានូវប្រសិទ្ធភាពការងារ។ ទន្ទឹមនេះ ក្រសួងមុខងារសាធារណៈ ក្នុងនាមជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា និងក្នុងនាមជាស្ថាប័នដឹកនាំនិងសម្របសម្រួលកម្មវិធីជាតិកែទម្រង់រដ្ឋបាល

សាធារណៈ បានរៀបចំយន្តការស្ថាប័នពេញលេញ និងសមស្របដើម្បីគាំទ្រដល់ដំណើរការនៃការកែទម្រង់រដ្ឋបាលសាធារណៈ។ ការកែសម្រួលនិងការរៀបចំទាំងនេះ ត្រូវបានអនុវត្តដោយឆាប់រហ័ស និងទាន់ពេលវេលាស្របតាមការចង្អុលទិសរបស់ **សម្តេចមហាបវរធិបតី** គឺ "**រៀបចំផ្ទះខ្លួនយើងឱ្យរៀបរយជាមុន មុននឹងអនុវត្តការងារផ្សេងទៀត**"។

២. ការគ្រប់គ្រងវិស័យមុខងារសាធារណៈត្រូវបានកែលម្អជាលំដាប់ តាមរយៈការដាក់ចេញជាបន្តបន្ទាប់នូវលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ រួមជាមួយនឹងការពង្រឹងការគ្រប់គ្រងមន្ត្រីក្របខណ្ឌនិងមន្ត្រីជាប់កិច្ចសន្យា ការគ្រប់គ្រងការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល ការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការនៅរៀងរាល់ពីរសប្តាហ៍ម្តង ទៅតាមប្រព័ន្ធធនាគារ ការរៀបចំដំឡើងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗជាបន្តបន្ទាប់ជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ មន្ត្រីជាប់កិច្ចសន្យា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការរៀបចំដំឡើងរបបសន្តិសុខសង្គមប្រចាំខែជូននិវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន ព្រមទាំងការរៀបចំផ្តល់ប្រាក់ឧបត្ថម្ភ ក្នុងឱកាសពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិនិងពិធីបុណ្យភ្ជុំបិណ្ឌ ការងារវិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យមុខងារសាធារណៈ ពិសេសការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារនិងការគ្រប់គ្រងមន្ត្រីរាជការ ដែលត្រូវបានផ្ទេរនៅក្នុងវិស័យអប់រំ ការលើកកម្ពស់សមភាពយេនឌ័រនិងជនមានពិការភាព ការពង្រឹងអធិការកិច្ចមុខងារសាធារណៈ និងការងារទំនាក់ទំនងអន្តរជាតិនិងអាស៊ាន

៣. ក្រសួងមុខងារសាធារណៈ បានជំរុញនិងផ្តល់ការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការរបស់ក្រសួង ស្ថាប័ន តាមរយៈការបណ្តុះបណ្តាលនិងសិក្ខាសាលាផ្សេងៗ ពិសេសនៅសាលាភូមិន្ទរដ្ឋបាល ដែលបាននិងកំពុងធ្វើការបណ្តុះបណ្តាលមន្ត្រីរាជការ រួមមានវគ្គបណ្តុះបណ្តាលដំបូង

វគ្គបណ្តុះបណ្តាលបន្ត និងការបណ្តុះបណ្តាលវគ្គខ្លីៗជាច្រើនទៀត ក្នុងក្របខណ្ឌផ្តល់ដោយក្រសួងមុខងារសាធារណៈ និងក្របខណ្ឌសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍអន្តរជាតិ

៤. ប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងមន្ត្រីរាជការ ត្រូវបានធ្វើការអភិវឌ្ឍជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងមុខងារសាធារណៈ ស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថល២០២១-២០៣៥ រួមមាន ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាថ្មីក្នុងការគ្រប់គ្រងទិន្នន័យមន្ត្រីរាជការឱ្យបានពេញលេញ ការរៀបចំតារាងទូទាត់បៀវត្ស ប្រព័ន្ធគ្រប់គ្រងសលាកប័ត្រព័ត៌មានមន្ត្រីរាជការស៊ីវិល ប្រព័ន្ធគ្រប់គ្រងការចូលនិវត្តន៍ ប្រព័ន្ធព័ត៌មានមន្ត្រីរាជការស៊ីវិល ប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់ប្រាក់ម៉ោងបន្ថែមសម្រាប់មន្ត្រីអប់រំ ប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យានិងគ្រូជាប់កិច្ចសន្យា ប្រព័ន្ធគ្រប់គ្រងចរន្តឯកសារ និងប្រព័ន្ធគ្រប់គ្រងសលាកប័ត្រព័ត៌មានមន្ត្រីរាជការស៊ីវិលក្នុងបណ្ណសារក្រសួងមុខងារសាធារណៈ ការបង្កើនសុវត្ថិភាពក្នុងការបញ្ចូលទិន្នន័យ ការរៀបចំអត្តសញ្ញាណបណ្ណមន្ត្រីរាជការប្រភេទថ្មីជាទម្រង់ស្មាតកាតដែលអាចប្រើប្រាស់ជាអត្តសញ្ញាណបណ្ណមន្ត្រីរាជការនិងជាបណ្ណអេធីអឹមសម្រាប់បើកប្រាក់បៀវត្ស និងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងការជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ

៥. ក្រសួងមុខងារសាធារណៈ បានបំពេញការងារនិងសម្រេចបានលទ្ធផលជាបន្តបន្ទាប់ក្នុងក្របខណ្ឌនៃ**ការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈពាក់ព័ន្ធនឹង៖**

## ៥.១ ការកែលម្អការជ្រើសរើសមន្ត្រីបម្រើការងារក្នុងរដ្ឋបាលសាធារណៈ

- ក្រសួងមុខងារសាធារណៈបានដឹកនាំ និងសម្របសម្រួលការរៀបចំអនុក្រឹត្យ ស្តីពីការដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ព្រមទាំងបានដឹកនាំនិងរៀបចំការ

ប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ស្របតាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** គឺ "**ជាប់ដោយមោទនៈ ធ្លាក់ដោយអស់ចិត្ត**"

- ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ត្រូវបានអនុវត្តចំនួន៥ លើក គឺ៖ ការប្រឡងជ្រើសរើសមន្ត្រីកសិកម្មឃុំ/សង្កាត់ចំនួន២៥០នាក់ ការជ្រើសរើសគ្រូបង្រៀនឯកទេសអប់រំកាយ និងកីឡា ការជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌអង្គភាពប្រឆាំងអំពើពុករលួយ ការជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌក្រសួងសាធារណការនិងដឹកជញ្ជូន និងការជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ លើសពីនេះ គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសគ្រូបង្រៀនអនុវិទ្យាល័យក្នុងក្របខណ្ឌនៃក្រសួងអប់រំ យុវជន និងកីឡា ក៏បានចេញសេចក្តីសម្រេចទទួលស្គាល់បេក្ខជនចូលរួមការប្រឡងប្រជែង ដែលមានចំនួន ៣៣ ៣១៤ នាក់ ហើយដែលគ្រោងរៀបចំការប្រឡងប្រជែង នៅដើមខែឧសភា ឆ្នាំ២០២៤
- ក្រុមការងារបច្ចេកទេសនៃក្រសួងមុខងារសាធារណៈ បានរៀបចំសេចក្តីព្រាងឯកសារទស្សនាទាន និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការជ្រើសរើសនិងគ្រប់គ្រងមន្ត្រីបច្ចេកទេស/មន្ត្រីជំនាញ ផ្អែកលើកិច្ចសន្យា ដើម្បីគាំទ្រដល់ការគ្រប់គ្រង និងប្រើប្រាស់មន្ត្រីឱ្យមានប្រសិទ្ធភាពខ្ពស់ និងឆ្លើយតបនឹងសេចក្តីត្រូវការនៃការងារនិងអង្គភាពនីមួយៗ របស់ក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ

### ៥.២ ការពង្រឹងសមត្ថភាពនិងសមិទ្ធកម្មស្ថាប័នដើម្បីលើកកម្ពស់គុណភាពការងារ

- ក្រុមការងារបច្ចេកទេសនៃក្រសួងមុខងារសាធារណៈ បានរៀបចំសេចក្ដីព្រាងឯកសារទស្សនាទាន សេចក្ដីណែនាំស្ដីពីការពិនិត្យឡើងវិញការវិភាគមុខងាររចនាសម្ព័ន្ធក្រសួង ស្ថាប័ន ការរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំនិងអង្គភាពសុខាភិបាលនៅមូលដ្ឋាន ព្រមទាំងបានរៀបចំសេចក្ដីព្រាងក្រមសីលធម៌វិជ្ជាជីវៈ
- កម្មវិធីបណ្ដុះបណ្ដាល ដើម្បីពង្រឹងសមត្ថភាពនិងភាពជាអ្នកដឹកនាំអង្គភាពរបស់ថ្នាក់ដឹកនាំនិងមន្ត្រីជាន់ខ្ពស់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបន្តអនុវត្តដោយសាលាភូមិន្ទរដ្ឋបាល

### ៥.៣ ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម

- សេចក្ដីព្រាងឯកសារទស្សនាទាន ស្ដីពីប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មនិងកម្មវិធីលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ត្រូវបានគិតគូរនិងរៀបចំជាបណ្ដើរៗ

៦. ក្រសួងមុខងារសាធារណៈ បានបំពេញតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័ន ដោយបានរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលឆ្នាំ២០២៣ និងបានរៀបចំពិធីប្រកាសទទួលស្គាល់អង្គភាពជ័យលាភីចំនួន៣០ រួមមាន៖ អនុវិទ្យាល័យចំនួន១០ សាលាបឋមសិក្សាចំនួន១០ មណ្ឌលសុខភាពចំនួន១០ និងបានប្រកាសដាក់ឱ្យអនុវត្តការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈគំរូវិទ្យាល័យ សាលាមត្តេយ្យសិក្សា និងមន្ទីរពេទ្យបង្អែក សម្រាប់ឆ្នាំ២០២៤

៧. ក្រសួងមុខងារសាធារណៈ ក៏បានរៀបចំរួចរាល់នូវសេចក្តីព្រាងផែនការសកម្មភាពអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា សម្រាប់ឆ្នាំ២០២៤ ដល់ ២០២៨ ហើយដែលគ្រោងដាក់ឆ្លងការពិនិត្យសម្រេចឱ្យបានរួចរាល់សម្រាប់ការដាក់ឱ្យអនុវត្តក្នុងត្រីមាសទី២ ឆ្នាំ២០២៤។ ទន្ទឹមនេះ សេចក្តីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ក៏ត្រូវបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពឱ្យបានសមស្រប ដើម្បីប្រើប្រាស់ជាផែនទីចង្អុលផ្លូវរយៈពេលមធ្យមនិងវែងក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ។

ក្រៅពីនេះ យើងនៅមានសមិទ្ធផលជាច្រើនទៀតដែលមានបង្ហាញជូនលម្អិតនៅក្នុងរបាយការណ៍បូកសរុបសមិទ្ធផលការងារ របស់ក្រសួងមុខងារសាធារណៈ ឆ្នាំ២០២៣ ដែលនឹងបង្ហាញជូនដល់អង្គពិធីនៅពេលបន្ទាប់ ហើយឯកឧត្តម លោកជំទាវ លោក លោកស្រី ក៏អាចស្កេន QR code ដើម្បីទទួលបានរបាយការណ៍នេះ និងឯកសារផ្សេងទៀតនៃអង្គសន្និបាតផងដែរ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា!**

ខ្ញុំពិតជាមានមោទនភាពខ្ពស់ចំពោះការបោះជំហានឆ្ពោះទៅមុខ នៃវិស័យមុខងារសាធារណៈ ដែលបាននិងកំពុងចូលរួមចំណែកដល់ការលើកកម្ពស់អភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ ដែលជាមូលដ្ឋានចាំបាច់ក្នុងការជំរុញល្បឿននៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ សមិទ្ធផលទាំងនេះ អាចសម្រេចទៅបានអាស្រ័យដោយកត្តាសំខាន់ ៣ យ៉ាងគឺ៖

១. កត្តាគោលនយោបាយ និងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ជាពិសេស យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យឆ្នាំ២០៥០ កម្ពុជាក្លាយជាប្រទេសមានចំណូលខ្ពស់

២. កត្តាផ្ទៃក្នុងនៃក្រសួងមុខងារសាធារណៈ គឺដោយសារតែយើង មានចក្ខុវិស័យធន្ទៈ និងផែនការច្បាស់លាស់ មានរចនាសម្ព័ន្ធការងារត្រឹមត្រូវ មានប្រព័ន្ធការងារល្អ និងជាពិសេស មានថ្នាក់ដឹកនាំនិងមន្ត្រីគ្រប់កម្រិតដែលមានជំនាញ សមត្ថភាពខ្ពស់ និងបំពេញការងារឈរលើ **មូលដ្ឋានអភិក្រមបុរេសកម្ម និងសកម្ម** យោគយល់ អធ្យាស្រ័យ សហការគ្នា ស្មារតីជាក្រុម និងទទួលខុសត្រូវខ្ពស់ទៅតាមជំនាញនិងភារកិច្ចរៀងៗខ្លួន

៣. កត្តាចូលរួមរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធទាំងអស់ជាមួយក្រសួងមុខងារសាធារណៈ គឺជាលក្ខខណ្ឌដ៏ចាំបាច់និងមិនអាចខ្វះបាន ដែលជានាឱ្យសម្រេចបាននូវសមិទ្ធផលជាច្រើន នាពេលកន្លងមក និងដែលត្រូវសម្រេចបន្ថែមទៀតនាពេលខាងមុខ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាថ្នាក់ដឹកនាំនិងមន្ត្រីគ្រប់លំដាប់ថ្នាក់របស់ក្រសួងមុខងារសាធារណៈ ដែលបានខិតខំបំពេញការងារតាមតួនាទីនិងភារកិច្ចយ៉ាងសកម្មប្រកបដោយស្មារតីទទួលខុសត្រូវ និងការប្តេជ្ញាចិត្តដ៏មោះមុតក្នុងការសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងវិស័យមុខងារសាធារណៈ និងការកែទម្រង់រដ្ឋបាលសាធារណៈជូនរាជរដ្ឋាភិបាល។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងដៃគូអភិវឌ្ឍទាំងអស់ ដែលបានផ្តល់កិច្ចសហការកន្លងមកក្នុងការអភិវឌ្ឍវិស័យមុខងារសាធារណៈនិងការកែទម្រង់រដ្ឋបាលសាធារណៈ ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា!**

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលការងារ ដូចបានរៀបរាប់ពីខាងដើម យើងនៅមានបញ្ហាប្រឈមដ៏ស្មុគស្មាញជាច្រើន មានដូចជាបញ្ហាវិបត្តិសង្គមសេដ្ឋកិច្ចក្រោយជំងឺកូវីដ-១៩ ភាពតានតឹងខាងភូមិសាស្ត្រនយោបាយ ការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចនិងពាណិជ្ជកម្ម និងបញ្ហាគ្រោះធម្មជាតិជាដើម ដែលបាន

ជះឥទ្ធិពលជាអវិជ្ជមានដល់សង្គមជាតិយើង។ លើសពីនេះ សេចក្តីត្រូវការរបស់ប្រជាជនមានការកើនឡើងជាលំដាប់ ហើយការរំពឹងរបស់ប្រជាជនចំពោះអ្វីដែលរាជរដ្ឋាភិបាលត្រូវសម្រេចឱ្យបានក៏កើនឡើងជាលំដាប់ដែរ។ ប្រឈមនឹងបញ្ហាទាំងនេះ ក្រសួងមុខងារសាធារណៈ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំនិងសម្របសម្រួលការងារកែទម្រង់អភិបាលកិច្ច ដែលជាស្នូលនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ត្រូវប្រឹងប្រែងថែមទៀត ប្រកបដោយភាពអត់ធ្មត់ ម្ចាស់ការ និងសហការឱ្យកាន់តែជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការកសាងរដ្ឋបាលទំនើប ដើម្បីនាំនាវាកម្ពុជាឆ្ពោះទៅសម្រេចបាន**ចក្ខុវិស័យឆ្នាំ២០៥០**។

ដើម្បីបំពេញនូវបេសកកម្មដ៏ថ្លៃថ្លានិងប្រកបដោយកិត្តិយសនេះ បន្ថែមទៅលើអ្វីដែលក្រសួងសម្រេចបាននាពេលកន្លងមក ក្រសួងមុខងារសាធារណៈ ចាំបាច់ត្រូវកំណត់ទិសដៅសម្រាប់ជំហានបន្ទាប់ ដោយផ្តើមចេញពីការកំណត់បានច្បាស់លាស់នូវបញ្ហាប្រឈមនាពេលបច្ចុប្បន្ន ចំណុចខ្លាំង និងចំណុចខ្សោយ និងដាក់ចេញនូវយុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាពនានាដែលអាចដោះស្រាយនូវបញ្ហាប្រឈមទាំងនោះបាន ដើម្បីឈានទៅដល់ការពង្រឹងអភិបាលកិច្ចនិងការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើបមានសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំដែលអាចបម្រើប្រជាជនបានកាន់តែប្រសើរឡើង។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា!**

សន្និបាតថ្ងៃនេះគឺជាឱកាសដ៏សំខាន់សម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់ក្រសួងមុខងារសាធារណៈ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានការពាក់ព័ន្ធធ្វើការពិនិត្យ និងវាយតម្លៃលើការងារកន្លងមក កំណត់បញ្ហាប្រឈម និងពិភាក្សាស្វែងរកវិធីសាស្ត្រថ្មីៗដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ និងលើកទិសដៅការងារបន្តក្នុងក្របខណ្ឌនៃការគ្រប់គ្រងនិងអភិវឌ្ឍវិស័យមុខងារសាធារណៈ និងការកែលម្អរដ្ឋបាលសាធារណៈ។ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា នឹងប្រើប្រាស់ឱកាសនេះឱ្យអស់លទ្ធភាព ដោយលើកឡើងនូវបញ្ហា

ប្រឈមឱ្យបានចំៗ និងពិភាក្សាផ្លាស់ប្ដូរយោបល់ឱ្យបានផុសផុល ទៅតាមប្រធានបទដែលបានកំណត់ ដើម្បីជាមូលដ្ឋានសម្រាប់ការកំណត់ទិសដៅ យុទ្ធសាស្ត្រ និងរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំបន្ទាប់។

ជាទីបញ្ចប់ ក្នុងនាមក្រសួងមុខងារសាធារណៈនិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា សមាជិកសមាជិកានៃអង្គពិធីទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើក **សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២៤ របស់ក្រសួងមុខងារសាធារណៈ** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ !**